**អភិបូជារាត្រីអបអរសាទរព្រះយេស៊ូប្រសូត**
**នៅព្រះសហគមន៍ព្រះកុមារយេស៊ូ បឹងទំពន់**
**ភ្នំពេញខាងត្បូង ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២២**

**"ព្រះអំណោយទាននៃព្រះយេស៊ូប្រសូត ផ្លាស់ប្តូរពិភពលោក"**

បងប្អូនជាទីស្រឡាញ់

មុនចាប់ផ្តើមចែករំលែកអំពីបុណ្យដ៏ពិសេស ដែលយើងគោរពថ្ងៃនេះគឺ "**ព្រះយេស៊ូប្រសូត**"។ ខ្ញុំសូមស្វាគមន៍បងប្អូនទាំងអស់ ដែលមកយ៉ាងច្រើនកុះករនៅក្នុងយប់ដ៏សុខសាន្តនេះ យើងមានបងប្អូនដែលធ្លាប់ចូលព្រះវិហារព្រះកុមារយេស៊ូ បឹងទំពុន ជាប្រចាំ យើងមានបងប្អូនដែលប្រហែលមកពីកន្លែងផ្សេងៗដែលបានចូលរួមជាមួយយើង។ ប្រហែលយើងមានបងប្អូនគ្រីស្តបរិស័ទ រួមជាមួយពុទ្ធបរិស័ទខ្លះៗ ដែលបានចូលនៅក្នុងអំណរសប្បាយរបស់ព្រះសហគមន៍កាតូលិកយើង។

ថ្ងៃនេះ យើងឃើញមានបងស្រីមេត្តាករុណាយ៉ាងច្រើន ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះបងស្រី **ជូសែប** ដែលជាបងស្រីបន្តតួនាទីទទួលខុសត្រូវក្រុមបងស្រីមេត្តាករុណានៅក្នុងពិភពលោកពីម្តាយតេរេសា។ ដូច្នេះ ថ្ងៃនេះជាមោទនភាពនិងជាកិត្តិយសរបស់យើង នៅក្នុងអំណរសប្បាយសូមទទួលស្វាគមន៍បងស្រី។

ថ្ងៃនេះ ឈានចូល១៤ឆ្នាំដែលសម្តេចប៉ាបបានប្រកាសលោក អូលីវីយេ៍ ជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ម៉ោង៦ល្ងាច។ បងប្អូនជាទីស្រឡាញ់ ពិតមែនយើងបានស្តាប់សេចក្តីរបស់ក្រុមទេវទូត "**ច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គបានប្រកបដោយសេចក្តីសុខសាន្តនៅលើផែនដី**"។ យប់នេះ យើងចេញពីការធ្វើដំណើររបស់យើងអស់រយៈពេល៤អាទិត្យ នៅក្នុងរដូវរង់ចាំ។ យើងចេញពីភាពងងឹតនៃដួងចិត្តរបស់យើង យើងចេញពីកម្លាំងដែល

យើងបានប្រមូល ដើម្បីខិតខំ។ ដូចខ្ញុំបានអញ្ជើញបងប្អូនប៉ុន្មានដងនៅក្នុង៤អាទិត្យនេះ ខិតខំ ដើម្បីកែប្រែចិត្តគំនិត ប្រែរបៀបរស់នៅ ប្រែរបៀបដែលយើងមើលឃើញស្ថានភាពនៅក្នុងពិភពលោក ដើម្បីមើលឃើញស្ថានភាពនៃពិភពលោកដោយភ្នែកថ្មី។ ភ្នែករបស់ព្រះជាម្ចាស់ផ្ទាល់ ព្រះនេត្រារបស់ព្រះអង្គផ្ទាល់ ដើម្បីណែនាំឲ្យផ្កាឈូកដែលយើងមាននៅក្នុងដួងចិត្តរបស់យើង ដែលជាប់ភក់នៃភាពងងឹត អាចរីកចម្រើនលូតលាស់នៅក្រោមព្រះអាទិត្យរបស់ព្រះជាម្ចាស់ ទៅជាផ្កាមួយដ៏ស្អាតបំផុតដែលទាំងអស់គ្នាចង់បេះនៅក្នុងយប់ដ៏សុខសាន្តនេះ។

ពិតមែន យប់នេះជាពេលវេលាដើម្បីមើលឃើញដោយភ្នែករបស់យើងផ្ទាល់ ផ្កាយមួយដ៏ពិសេស ពន្លឺដ៏ត្រចះត្រចង់មួយយ៉ាងពិសេស ដែលកំពុងរះឡើងនៅក្នុងផ្ទៃមេឃរបស់យើង។ យប់នេះ គឺព្រះជាម្ចាស់ដែលបង្ហាញអំពី ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គដល់មនុស្សលោក។ យប់នេះ យើងអាចប្រកាសថា "**ព្រះសង្គ្រោះបានប្រសូតហើយ**"។

បងប្អូនជាទីស្រឡាញ់ ដើម្បីមើលឃើញការអស្ចារ្យដែលកំពុងកើតឡើងនៅពេលហ្នឹង ដើម្បីមើលឃើញព្រះសង្គ្រោះប្រសូតសម្រាប់យើងនៅក្នុងយប់នេះ។ យើងមានសញ្ញាដ៏តូចតាចសាមញ្ញបំផុត ដែលតាមពិតភ្នែករបស់យើងមើលមិនឃើញ។ ដោយសារ ដើម្បីមើលឃើញព្រះសង្គ្រោះប្រសូត៖

**សញ្ញាទី១** ដែលយើងមានគឺ មានផ្កាយមួយដែលភ្លឺជាងគេនៅក្នុងចំណោមផ្កាយទាំងឡាយ។ ផ្កាយមួយដ៏តូច មានតែហោរាចារ្យបានមើលឃើញ មើលឃើញនៅក្នុងចំណោមផ្កាយរាប់ពាន់លាន មានតែមួយដែលប្លែក មានតែមួយដែលភ្លឺជាងគេ។

**សញ្ញាទី២** ដែលយើងទទួលយប់នេះ គឺកូនង៉ែតដែលបានកើត នៅក្នុងចំណោមកូនង៉ែតច្រើនណាស់។ ដោយសារ ពីមួយយប់ទៅមួយយប់មានកូនង៉ែតប៉ុន្មានលាននាក់ដែលកើតជារៀងរាល់ថ្ងៃ។ នៅក្នុងចំណោមកូនង៉ែតនេះ មានមួយដែលព្យាការីអាណា បានមើលឃើញ ដែលស៊ីមេអង់បានមើលឃើញ។ នៅក្នុងចំណោមកូនង៉ែតទាំងអស់ នៅពេលលោកតាស៊ីមេអង់បានមើលឃើញព្រះឱរសព្រះយេស៊ូ បានយល់ថា នេះជាព្រះពន្លឺដែលយាងមក។

ពិតមែន បងប្អូនជាទីស្រឡាញ់ដើម្បីមើលឃើញសញ្ញាសម្គាល់ដ៏ពិសេសនៅយប់នេះ ជាសញ្ញាសម្គាល់ដែលសាមញ្ញបំផុត។ យើងត្រូវការលាងជម្រះចិត្តគំនិតរបស់យើង ដើម្បីទទួលចិត្តគំនិត និងជាពិសេសបេះដូងដូចកូនក្មេងម្នាក់ ដែលចេះមើលឃើញការអស្ចារ្យដ៏តូចតាច។

បងប្អូនជាទីស្រឡាញ់ យប់នេះជាពេលវេលាដើម្បីធ្វើតេស្ត អំពីរបៀបដែលយើងបានរៀបចំបុណ្យព្រះយេស៊ូប្រសូតអស់រយៈពេល៤អាទិត្យ។ **តើយើងកំពុងមើលឃើញអ្វីខ្លះ នៅក្នុងភាពងងឹតនៃចិត្តគំនិតរបស់យើង? តើយើងកំពុងស្តាប់ឮអ្វីខ្លះ នៅក្នុងត្រចៀករបស់យើង?** ខ្ញុំជឿថាចម្លើយរបស់យើងស៊ីសងលើរបៀប ដែលយើងយកចិត្តទុកដាក់ត្រៀបអស់រយៈពេល៤អាទិត្យដើម្បីទទួលស្វាគមន៍ព្រះពន្លឺកើតជាមនុស្សនៅក្នុងយប់នេះ។ បងប្អូនជាទីស្រឡាញ់ នៅក្នុង៤អាទិត្យកន្លងមក ខ្ញុំបានមើលឃើញសញ្ញាច្រើន ខ្ញុំបានស្តាប់ឮអំណរសប្បាយដ៏ពិសេស ខ្ញុំបានរំភើបចិត្តយ៉ាងច្រើនតាមកន្លែងនីមួយៗនៅក្នុងភូមិភាគភ្នំពេញ។

ខ្ញុំនឹកឃើញបងប្អូន២០០នាក់ដែលបានមកហូបបាយនៅបឹងទំពន់នេះ ដើម្បីចូលរួមមហាជប់លៀងនៃបុណ្យព្រះយេស៊ូប្រសូត។ ខ្ញុំនឹកឃើញអំណរសប្បាយ ដែលគេមាននៅពេលយើងបានស្វាគមន៍គេយ៉ាងកក់ក្តៅនៅព្រះសហាគមន៍ព្រះកុមារយេស៊ូយើង។

ខ្ញុំបាននឹកឃើញកូនក្មេងសាលាមត្តេយ្យ ដែលបានបញ្ចប់ការសិក្សារបស់គេ បន្ទាប់ពីមិនបានរៀនអស់រយៈពេលពីរឆ្នាំ ដោយសារកូវីដ-១៩។ ពេលខ្ញុំស្តាប់ឮកូនក្មេងដែលបានប្រកាសយ៉ាងច្បាស់លាស់ នៅថ្ងៃអនាគតខ្ញុំចង់ធ្វើជាលោកគ្រូអ្នកគ្រូ ចង់ធ្វើជាប៉ូលីស ចង់ធ្វើជាគ្រូពេទ្យ។ ខ្ញុំនឹកឃើញសញ្ញានៃវត្តមានរបស់ព្រះយេស៊ូពិតមែន។

នៅពេលខ្ញុំបានស្តាប់ឮសំឡេងអស្ចារ្យនៃអំណរសប្បាយ ដែលហៀរពីដួងចិត្តរបស់សិស្សានុសិស្សរបស់សាលាវិទ្យាល័យចំណេះទូទៅសន្តប្រេង់ស្ទ័រ និងវិទ្យាល័យបច្ចេកទេសសន្តប្រេង់ស្ទ័រ។ ពីម្សិលមិញ បានជាប់បាក់ឌុប ១០០% ខ្ញុំបានឃើញវត្តមានរបស់ព្រះជាម្ចាស់ដែលបានកើតឡើង។

នៅពេលខ្ញុំបានស្តាប់ឮឪពុកម្តាយនៃកូនក្មេងអូទីស៊ឹម ដែលបានជួបជុំគ្នាពីម្សិលមិញនៅបឹងទំពន់នេះ។ នៅពេលខ្ញុំស្តាប់ឮសេចក្តីសង្ឃឹមរបស់ពួកគាត់ សុបិនរបស់ពួកគាត់ ដែលឃើញកូនរបស់គេដែលកំពុងរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ នៅក្នុងរបៀបតូចតាចមែន ប៉ុន្តែការរីកចម្រើននេះជាអំណរសប្បាយរបស់ពួកគាត់ នៅក្នុងសាលាអប់រំពិសេសដើម្បីការលូតលាស់។

នៅពេលខ្ញុំឃើញកូនក្មេង ប៉ុន្មានថ្ងៃមុននៅគ្រួសារពន្លឺមិត្តភាព នៅពេលនោះខ្ញុំបានឃើញកូនក្មេងសប្បាយណាស់។ នៅពេលគេឃើញឪពុកម្ដាយ ដែលជាកម្មករផ្ដល់សក្ខីភាពអំពីកម្លាំងដែលគេមាន ដើម្បីបន្តតស៊ូ ដើម្បីបន្តឈ្នះឧបសគ្គនានាសម្រាប់កូនគេឲ្យមានអនាគត។

នៅពេលខ្ញុំបានទៅកោះកុង ខ្ញុំបានឃើញគ្រួសារក្រីក្រដែលជួបជុំគ្នាជាមួយព្រះសហគមន៍របស់យើង។ មានប៉ុន្មាននាក់ជាមនុស្សឯកោមែនទែន ប៉ុន្តែនៅពេលហ្នឹងគេបានទទួលបទពិសោធន៍នៃគ្រួសារដ៏កក់ក្ដៅ ដែលស្វាគមន៍និងស្រឡាញ់គេ។

នៅពេលខ្ញុំមើលឃើញ តាមព្រះសហគមន៍នីមួយៗនៅក្នុងភូមិភាគ របៀបដែលបានរៀបចំការសម្ដែងរឿងព្រះយេស៊ូប្រសូតសម្រាប់យប់នេះ។ ឆ្នាំនេះ បានខិតខំមែនទែន ទាំង៥០កន្លែងដែលយើងមាននៅក្នុងភូមិភាគភ្នំពេញ ដើម្បីឲ្យការសម្ដែងរឿងព្រះយេស៊ូប្រសូតទៅជាអំណរសប្បាយសម្រាប់មហាជន ដែលកំពុងមកដើម្បីកំពុងជួបគ្នានៅគ្រប់ទីកន្លែងនៅក្នុងភូមិភាគភ្នំពេញពីម្សិលមិញ ថ្ងៃនេះ ថ្ងៃស្អែក។

នៅពេលខ្ញុំបានមើលឃើញភ្នែករបស់កូនក្មេង ដែលកំពុងពោរពេញដោយអំណរសប្បាយដោយសារគេសម្លឹងមើលពេងព្រះយេស៊ូប្រសូត គេសម្លឹងមើលពន្លឺដែលយើងបានយកចិត្តទុកដាក់រៀបចំមែនទែន។ នៅឆ្នាំនេះ នៅក្នុងព្រះសហគមន៍នីមួយៗយើងមានភូមិបេថ្លេហិមដែលបានកើតឡើង។ ខ្ញុំសូមអរគុណដល់ព្រះសហគមន៍ទាំងអស់ដែលបានយកចិត្តទុកដាក់មែនទែនដើម្បីបង្ហាញអំណរសប្បាយដែលយើងមាន តាមរយៈសញ្ញាដ៏តូចតាច។

ពិតមែនបងប្អូនជាទីស្រឡាញ់ សញ្ញាសំគាល់នេះទាំងអស់ ណែនាំឲ្យយើងរំភើប ណែនាំឲ្យយើងចូលរួមជាមួយព្រះនាងម៉ារីនិងសន្តយ៉ូសែប ដើម្បីសម្លឹងមើលព្រះយេស៊ូដែលប្រសូតហើយ។ ខ្ញុំជឿថាបងប្អូនទាំងអស់មានសញ្ញាផ្សេងៗ ដែលបានមើលឃើញដែរ ណែនាំឲ្យយប់នេះដួងចិត្តរបស់យើងភ្លឺដ៏អស្ចារ្យ។ ដែលណែនាំយប់នេះ ឲ្យចិត្តគំនិតរបស់យើងទៅជាចិត្តគំនិតដែលពោរពេញដោយសេចក្ដីសង្ឃឹមនិងកម្លាំងថ្មី។ ដោយសារយប់នេះ ក្ដីសុបិនរបស់យើងដែលចង់មានពិភពលោកប្រកបដោយសេចក្ដីសុខសាន្ត ប្រកបដោយសុខដុមរមនា យល់ថាអាចកើតឡើងបាន។ ដោយសារយប់នេះ សេចក្ដីសង្ឃឹមរបស់យើងដូចជាកើតសាជាថ្មី នៅក្នុងគោលបំណងឲ្យយើងមានពិភពលោកមួយប្រកបដោយយុត្តិធម៌ ដែលចេះគោរពព្រះជាម្ចាស់។

ខ្ញុំចង់សួរដល់បងប្អូនខ្ញុំនិយាយពិតឬអត់? តើបងប្អូនកំពុងមានក្តីសង្ឃឹមថ្មី? តើបងប្អូនកំពុងជឿថាក្តីសុបិនរបស់យើងកើតឡើងបាន? ដោយសារនេះជាការអស្ចារ្យនៃអាថ៌កំបាំង ដែលយើងកំពុងប្រារព្ធយប់នេះ គឺព្រះយេស៊ូប្រសូតហើយ។ ដោយសារយប់នេះ គឺព្រះជាម្ចាស់ផ្ទាល់ដែលប្រទានកាដូមួយដ៏អស្ចារ្យមែនទែន អំណោយទានមួយដ៏អស្ចារ្យមែនទែន គឺព្រះអំណោយទានរបស់ព្រះជាម្ចាស់ផ្ទាល់ ដើម្បីឲ្យយើងរស់នៅបច្ចុប្បន្ននេះនៅក្នុងលោកីយ៍នេះបាន នៅក្នុងសេចក្តីសុខ។ ទោះបីពិភពលោករបស់យើង មានមនុស្សយ៉ាងច្រើនដែលកំពុងកំសត់ទុរគត ដែលកំពុងឃំសោក។ ទោះបីពិភពលោករបស់យើង មានការស្អប់គ្នា ការច្រណែនគ្នាយ៉ាងច្រើន យើងដឹងថាយប់នេះនៅក្នុងចិត្តយើង យើងមានសេចក្តីសង្ឃឹម យើងមានកម្លាំងថ្មី ដោយសារ ព្រះយេស៊ូប្រសូតហើយ។ យប់នេះរួមជាមួយព្រះនាងម៉ារីនិងសន្តយ៉ូសែប រួមជាមួយគ្រូគង្វាលនិងទេវទូតទាំងឡាយ ជាពេលវេលាដើម្បីទទួលព្រះអំណោយទានរបស់ព្រះជាម្ចាស់ដ៏បរិបូណ៌ ពេញខ្លួនដើម្បីមានកម្លាំងថ្មី ថាមពលថ្មី ដើម្បីជម្រះចិត្តគំនិតរបស់យើង ដើម្បីឲ្យយើងធ្វើដំណើររួមជាមួយគ្នាពោរពេញដោយសេចក្តីក្លាហាន ពោរពេញដោយចិត្តអង់អាច។ ដោយដឹងថា កុំឲ្យខ្លាចអី យើងបានស្តាប់ហើយ ដោយមានយុត្តិធម៌នៅក្នុងចិត្តយើង ដោយគោរពកោតខ្លាចព្រះជាម្ចាស់ ដើម្បីឱ្យឆ្នាំថ្មីដែលជិតបើកហើយទៅជាឆ្នាំដ៏អស្ចារ្យ។

បងប្អូនជាទីស្រឡាញ់ ព្រះជាម្ចាស់ប្រទានឱ្យយើងច្រើនណាស់ និងយើងបានទទួលស្វាគមន៍។ ប៉ុន្តែ អ្វីៗទាំងអស់ស៊ីសងយើងផ្ទាល់ ស៊ីសងឆន្ទៈរបស់យើង ស៊ីសងចិត្តគំនិតរបស់យើង។ **តើយើងឯកភាពដើម្បីដូររបៀបដែលយើងរស់នៅប្រចាំថ្ងៃឬទេ? តើយើងឯកភាពដើម្បីដូរភ្នែករបស់យើង ដើម្បីមើលឃើញស្ថានភាពនៅក្នុងរបៀបថ្មីឬទេ? តើយើងឯកភាពដូររបៀបដែលយើងស្រឡាញ់ និងស្វាគមន៍បងប្អូនឯទៀតៗ ជាពិសេសមនុស្សតូចតាចឬទេ?** ពិតមែន ព្រះជាម្ចាស់ប្រទានការសង្គ្រោះ ព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្តដល់មនុស្សដែលព្រះអង្គស្រឡាញ់។ យប់នេះ យើងជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ យើងជាបុរសនិងស្ត្រីដែលព្រះជាម្ចាស់បានបង្កើតដែលព្រះជាម្ចាស់ស្រឡាញ់។ ប៉ុន្តែ អ្វីៗទាំងអស់ស៊ីសងលើយើង យើងទទួលឬមិនទទួល យើងដូរឬមិនដូរ យើងកែប្រែឬមិនកែប្រែ។

បងប្អូនជាទីស្រឡាញ់ រៀងៗខ្លួននៅក្នុងរាត្រីដ៏សុខសាន្តនេះ យើងមានក្តីសង្ឃឹម យើងមានសុបិនសម្រាប់ជីវិតរបស់យើងផ្ទាល់ សម្រាប់គ្រួសាររបស់យើង សម្រាប់សង្គមរបស់យើងបច្ចុប្បន្ននេះ។ ដោយព្រះអំណោយទានរបស់ព្រះជាម្ចាស់ យើងមានសមត្ថភាពដើម្បីឱ្យក្តីសុបិនរបស់យើងកើត

ឡើងបាន។ ប៉ុន្តែ លុះត្រាតែយើងខិតខំយកចិត្តទុកដាក់ តស៊ូ ស្រឡាញ់ និងយកព្រះជាម្ចាស់ជាទីពឹង ជាអាទិភាពនៅក្នុងជីវិតរបស់យើង។ យើងដឹងថា ប៉ុន្មានថ្ងៃទៀតយើងឆ្លងឆ្នាំចូលឆ្នាំ២០២៣ ដូច្នេះជាពេលវេលាដើម្បីជូនពរគ្នាទៅវិញទៅមក ឱ្យមានសុខភាពល្អ ឱ្យមានសេចក្តីសុខសាន្ត ...។ យើងមានពាក្យពិរោះៗយ៉ាងច្រើនដើម្បីជូនពរគ្នាទៅវិញទៅមក។ ប៉ុន្តែ ការជូនពររបស់យើងដែលបានជូនដល់បងប្អូនឯទៀតៗ អាចកើតឡើងបាននៅក្នុងព្រះយេស៊ូយប់នេះ លុះត្រាតែយើងយកចិត្តទុកដាក់អស់ពីសមត្ថភាព។

នរណាក៏ចង់មានសុខភាពល្អ ប៉ុន្តែ**តើយើងបានយកចិត្តទុកដាក់នឹងរូបកាយរបស់យើងឬទេ? តើយើងយកចិត្តទុកដាក់នឹងម្ហូបអាហារដែលយើងបរិភោគប្រចាំថ្ងៃឬទេ?** សុខភាពល្អ មិនមែនដោយសារថ្នាំទេ។

យើងចង់ក្លាយជាអ្នកមានដែលរកស៊ីបានស្រួល ប៉ុន្តែលុះត្រាតែក្មេងយើងយកចិត្តទុកដាក់រៀន លុះត្រាតែបងប្អូនដែលកំពុងធ្វើការខិតខំធ្វើការដោយសេចក្តីស្រឡាញ់ ដោយការទទួលខុសត្រូវជាន់ខ្ពស់។ មិនអាចក្លាយជាអ្នកមានដោយសារយើងទៅខ្ចីលុយគេ។

មានសេចក្តីសុខសាន្ត និងទំនាក់ទំនងយ៉ាងល្អរវាងគ្នានឹងគ្នាបាន លុះត្រាតែយើងអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក លុះត្រាតែយើងខិតខំស្វាគមន៍គ្នាទៅវិញទៅមកដោយតស៊ូនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ក៏ប៉ុន្តែ កុំសង្ឃឹមលើខិតប័ណ្ណដែលបង្ហោះលើបណ្តាញសង្គមរាល់ថ្ងៃដើម្បីបង្កើតទំនាក់ទំនងល្អ។

យើងចង់មានព្រះសហាគមន៍ដែលបើកចិត្តគំនិត ដែលចេះប្រកាសដំណឹងល្អ ដែលបំភ្លឺដល់បងប្អូនឯទៀតៗនៅក្នុងភូមិ នៅកន្លែងដែលយើងនៅបាន លុះត្រាតែយើងយកចិត្តទុកដាក់ទៅអភិបូជាជារៀងរាល់អាទិត្យ យើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់និងអនុវត្តតាមព្រះបន្ទូលនេះ។ យើងយកចិត្តទុកដាក់ចូលនៅក្នុងបេសកកម្ម និងសកម្មភាពតាមក្រុមនានាដែលយើងមាននៅតាមព្រះសហាគមន៍នីមួយៗ។ ប៉ុន្តែ ប្រសិនបើយើងសង្ឃឹមតែលើលោកឪពុក បងស្រី និងឧបដ្ឋាកតែប៉ុណ្ណឹង ព្រះសហាគមន៍របស់យើងមិនអាចលូតលាស់ និងរីកចម្រើនដើម្បីប្រកាសដំណឹងល្អបានទេ។

យើងចង់មានគ្រួសារដ៏សុខសាន្តបាន លុះត្រាតែយើងយកចិត្តទុកដាក់ស្តាប់គ្នាទៅវិញទៅមក យើងយកចិត្តទុកដាក់ជាមួយកូនរបស់យើង។ សួរកូនរបស់យើង **តើថ្ងៃនេះបានរៀនអ្វីខ្លះ? តើថ្ងៃនេះបានធ្វើអ្វីខ្លះ?** ប៉ុន្តែ ប្រសិនបើនៅពេលយើងជួបជុំគ្នាជាគ្រួសារ រៀងៗខ្លួនយើងរវល់តែមើលទូរស័ព្ទរបស់យើង គ្រួសារដ៏សុខសាន្តមិនអាចកើតឡើងបានទេ។

យើងចង់មានការត្រាស់ហៅយ៉ាងច្រើននៅក្នុងព្រះសហគមន៍ ជាពិសេសនៅឆ្នាំ២០២២យើងមានឧបដ្ឋាក៣រូប ដែលមានលោកបូជាចារ្យម្នាក់ ដែលមានលោកអភិបាលខ្មែរ១រូប។ យើងអាចធ្វើបាន លុះត្រាតែយើងជាលោកអភិបាល ជាបូជាចារ្យ ជាឧបដ្ឋាក ជាបងប្រុសបងស្រី យើងយកចិត្តទុកដាក់ដើម្បីផ្តល់សក្ខីភាពអំពីអំណរសប្បាយដែលយើងមាន ដើម្បីបម្រើព្រះសហគមន៍ និងបម្រើព្រះជាម្ចាស់។ យើងមិនអាចមានការត្រាស់ហៅយ៉ាងច្រើន ដោយសារយើងបើកការិយាល័យការត្រាស់ហៅនោះទេ។

បងប្អូនជាទីស្រឡាញ់ យប់នេះយើងស្តាប់ហើយស្តាប់ទៀត "**សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត ហើយសូមឱ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គ បានប្រកបដោយសេចក្តីសុខសាន្តនៅលើផែនដីនេះ**"។ សូមឱ្យបទចម្រៀងនេះ ចូលនៅក្នុងដួងចិត្តរបស់យើងពេញមួយឆ្នាំរួមជាមួយទេវទូត។ នៅពេលនេះ ខ្ញុំសូមជូនពរដល់បងប្អូនទាំងអស់ ឱ្យយើងមានពិធីនិងអំណរសប្បាយនៅក្នុងព្រះយេស៊ូប្រសូតដ៏អស្ចារ្យ ដើម្បីឱ្យដួងចិត្តរបស់យើងដែលទទួលស្វាគមន៍អំណោយទានពីព្រះកុមារយេស៊ូ ណែនាំឱ្យក្តីសុបិនរបស់យើងអាចក្លាយទៅជាការពិត។ និងដើម្បីឱ្យសេចក្តីសង្ឃឹមរបស់យើងនៅក្នុងឆ្នាំ២០២៣ ទៅជាសេចក្តីសង្ឃឹមមួយដ៏អស្ចារ្យមែនទែន ដែលផ្ទុះដូចកាំជ្រួច ដើម្បីឱ្យជីវិតរបស់យើងទៅជាជីវិតដ៏អស្ចារ្យនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

**ជយោព្រះយេស៊ូប្រសូត!**

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ

អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា

ភូមិភាគភ្នំពេញ